00665547

E9/26

DOCUMENT RECEIVED/DOCUMENT REÇU

ឯកសារទទួល

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 19 / 04 / 2011

ម៉ោង (Time/Heure): 14:36

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ការជូនដំណឹងអំពីការចូលរួមជាមួយនឹងសារណាបឋមរបស់លោក អៀង សារី ទាក់ទងនឹងឯកសារដែលត្រូវលើកយកមកសំអាងនៅសវនាការ & សារណាបន្ថែមទាក់ទងនឹងឯកសារថ្មី**

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Annebrecht VOSSENBERG (កម្មសិក្សាការីច្បាប់)

Alejandra CHAPA (កម្មសិក្សាការីច្បាប់)

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

00665548

០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

E9/26

# ការជូនដំណឹង & សារណា

១. កាលពីថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១១ សហមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ("មេធាវីការពារក្តី") បានដាក់សារណាបឋមរបស់ខ្លួនទាក់ទងនឹងឯកសារដែលនឹងត្រូវលើកយកមកសំអាងនៅក្នុងសវនាការ ("សារណារបស់ អៀង សារី")[1] ដើម្បីឆ្លើយតបទៅនឹងផ្នែកខ្លះនៃ "ដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យភាគីដាក់ឯកសារដើម្បីរៀបចំសវនាការ[2]"។ សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") តទៅនេះ សូមយល់ស្របតាមសារណារបស់លោក អៀង សារី ទាំងស្រុង និងសូមចូលរួមជាមួយក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីស្វែងរកដំណោះស្រាយជាក់លាក់ណាមួយដែលបានលើកឡើងនៅក្នុងសារណានោះ។

២. និយាយដោយសង្ខេប ដោយសារតែមូលហេតុដែលមាននៅក្នុងសារណារបស់លោក អៀង សារី ក្រុមមេធាវីការពារក្តីលោក នួន ជា៖ (ក) សូមសំអាងលើបញ្ជីឯកសារទាំងអស់នៅក្នុងសំណុំរឿងដែលបានដាក់ដោយក្រុមមេធាវីការពារក្តីលោក អៀង សារី ("បញ្ជីឯកសារ") (ខ) នៅពេលបច្ចុប្បន្ននេះ ក្រុមមេធាវីការពារក្តីលោក នួន ជា មិនត្រូវបានគេតម្រូវឲ្យ ហើយក៏មិនអាចបង្ហាញឯកសារជាក់លាក់ណាមួយចេញពីបញ្ជីឯកសារដែលខ្លួនមានបំណងលើកយកមកសំអាងក្នុងសវនាការបានឡើយ (គ) នៅពេលបច្ចុប្បន្ននេះ ក្រុមមេធាវីការពារក្តីលោក នួន ជា មិនត្រូវបានគេតម្រូវ ហើយក៏មិនអាចផ្តល់ "**តារាងភស្តុតាងឯកសារ**" ទាក់ទងនឹងសម្ភារៈដែលមានក្នុងសំណុំរឿងរួចហើយបានដែរ[3]។

---

[1] ឯកសារ No **E-9/22,** "បញ្ជីឯកសារបឋមរបស់លោក អៀង សារី ដែលមាននៅក្នុងសំណុំរឿង និងការជូនដំណឹងទាក់ទងនឹងបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង", ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១, ឯកសារ ERN 00659454–00659469។

[2] ឯកសារ No **E-9**, ដីកាបង្គាប់ឲ្យភាគីដាក់ឯកសារដើម្បីរៀបចំសវនាការ, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១, ឯកសារ ERN 00635754–00635759, កថាខណ្ឌទី១២ ដល់ទី១៤។

[3] សូមមើលសារណារបស់លោក អៀង សារី , កថាខណ្ឌទី១២ ដល់២៩។

៣. ជាងនេះទៅទៀត ទាក់ទងនឹងឯកសារថ្មីណាមួយដែលគេមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[4] ចំណុចខាងក្រោមនេះសមនឹងទទួលបានការបញ្ជាក់៖

ក) ដូចដែលបានគូសបញ្ជាក់ដោយមេធាវីការពារក្តីនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនៅពេលថ្មីៗនេះថា (បន្ថែមលើសារណាជាលាយលក្ខណ៍អក្សរដែលបានធ្វើឡើងកាលពីលើកមុន[5]) វានៅតែមិនទាន់ច្បាស់ "ថាតើក្រុមមេធាវីការពារក្តីលោក នួន ជា នៅតែត្រូវបានគេហាមឃាត់មិនឱ្យបើកការស៊ើបសួរក្នុងនាម[ជនជាប់ចោទ]នៅមុនពេលចាប់ផ្តើមសវនការសួរដេញដោល[6]ឬយ៉ាងណា"។ មកទល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូងមិនទាន់ចេញសេចក្តីណែនាំណាមួយទាក់ទងនឹងករណីនេះនៅឡើយទេ។

ខ) ការបញ្ជាក់ "ទាក់ទងនឹងការរៀបចំ និងតំណាក់កាលនៃការជំនុំជម្រះ[7]" ទើបតែត្រូវបានអង្គជំនុំជម្រះសាលាដំបូងប្រកាសនៅពេលថ្មីៗនេះតែប៉ុណ្ណោះ ។ បន្ទាប់ពីបានពិចារណាទៅលើលក្ខណៈបឋមនៃដំណាក់កាលជំនុំជម្រះក្តី ក្រុមមេធាវីការពារក្តីលោក នួន ជា មានបំណងលើកឡើងនូវប្រធានបទបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងប្រភេទផ្សេងៗគ្នា ដែលបានបញ្ជាក់នៅក្នុងសេចក្តីសង្ខេបរបស់សាក្សី ("សេចក្តីសង្ខេប[8]")។

គ) នៅពេលដែលភាគីផ្សេងៗគ្នាបានស្នើសុំឱ្យមានសាក្សីសរុបចំនួន១០៥៤នាក់ អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីបានពិនិត្យមើលបញ្ជីសង្ខេបសាក្សីស្របតាមវិធាន៨០ *ស្ទួន* និង ៨៧ នៃវិធានផ្ទៃក្នុង បានប្រកាសថា "វាប្រហែលជានឹងមានការកាត់បន្ថយចំនួនសាក្សីជាច្រើនដែល

---

[4] សូមមើលដីការបង្គាប់ឱ្យភាគីរៀបចំសវនាការ, កថាខណ្ឌទី១២ (ii)។

[5] សូមមើលឧទាហរណ៍ ឯកសារ **E-9/4/4**, "បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំ", ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ, ERN 00644417–00644423, "បញ្ជីឈ្មោះសាក្សីរបស់លោក នួន ជា", កថាខណ្ឌទី៦។

[6] ប្រតិចារិកព្រៀង, កិច្ចប្រជុំរៀបចំសវនាការ, ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១, ("ប្រតិចារិតអំពីកិច្ចប្រជុំរៀបចំសវនាការ"), 116:10–12។

[7] ប្រតិចារិតអំពីកិច្ចប្រជុំរៀបចំសវនាការ, 51:22–23។

[8] ឯកសារលេខ **E-9/10.1**, ឧបសម្ព័ន្ធ ឃ ៖"សេចក្តីសង្ខេបរបស់សាក្សីដោយមានចំណុចនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ឯកសារ ERN 00646679–00646736, តារាងបញ្ជីឈ្មោះសាក្សីរបស់លោក នួន ជា, កថាខណ្ឌទី១២។

នឹងត្រូវស្តាប់ចម្លើយនៅក្នុងសវនាការ[9]"។ ការកាត់បន្ថយចំនួនសាក្សីបែបនេះច្បាស់ជាប៉ះពាល់ដល់វិធីសាស្ត្រនៃការបង្ហាញឯកសាររបស់ក្រុមមេធាវីការពារក្តីលោក នួន ជា នៅក្នុងសវនាការលើអង្គសេចក្តីជាមិនខានឡើយ។

ឃ) ដូចដែលបានកត់សំគាល់ពីលើកមុនដោយមេធាវីការពារក្តី នួន ជា និងនៅក្នុងសារណារបស់ អៀង សារី *លក្ខណៈ និង ទំហំ* នៃសំណុំរឿង និងឃ្លាំងផ្ទុកឯកសាររួម ("SMD") ធ្វើឱ្យការកំណត់អត្តសញ្ញាណឯកសារដែលពាក់ព័ន្ធ និងការពន្យល់ពីឯកសារទាំងនោះទៅជនជាប់ចោទដើម្បីឱ្យគាត់ផ្តល់ព័ត៌មាន និងការណែនាំមកវិញកាន់តែមានភាពលំបាក និងត្រូវប្រើពេលវេលាច្រើន[10] ។

ង) ជាចុងក្រោយ ដូចដែលបានកត់សំគាល់នៅក្នុងសារណារបស់លោក អៀង សារី ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចែងពីការតម្រូវឱ្យផ្តល់ការជូនដំណឹងជាមុនទាក់ទងនឹងការដាក់ជូនសម្ភារៈថ្មីនៅសវនាការជំនុំជម្រះឡើយ "រហូតទល់នឹងការបិទពិភាក្សាដេញដោលជនជាប់ចោទ [...] អាច [...] នឹងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត"[11]។ ក្រុមមេធាវីការពារក្តី នួន ជា បានជំទាស់ជាបន្តបន្ទាប់ទៅនឹងការអនុវត្តប្រាកចាកពីនីតិវិធីជាធរមានរបស់កម្ពុជា ដែលមិនបានធ្វើយុត្តិកម្មដោយការយោងជាក់លាក់ចំពោះមាត្រា ១២ (១) នៃកិច្ចព្រមព្រៀង អវតក[12] ។

៤. ផ្អែកតាមកត្តាទាំងអស់នេះ និងក្នុងន័យជួយដល់អង្គជំនុំជម្រះដើម្បីបំពេញភារកិច្ចរបស់ខ្លួនក្នុងការថ្លឹងថ្លែងសម្ភារៈទាំងអស់ឱ្យបានគ្រប់ជ្រុងជ្រោយ [...] ដែលត្រូវចោទថាជាភស្តុតាងដោះបន្ទុក[13] ក្រុមមេធាវីការពារក្តី នួន ជា នឹងប្រឹងប្រែងជូនដំណឹងទៅអង្គជំនុំជម្រះ និងភាគីអំពី

---

[9] ប្រតិចារិកអំពីការរៀបចំសវនាការ, 53:3-5។

[10] សូមមើលបញ្ជីឈ្មោះសាក្សីរបស់ នួន ជា នៅត្រង់កថាខណ្ឌទី២ ។ សារណារបស់ អៀង សារី នៅត្រង់កថាខណ្ឌទី ៣០ ដល់ ៣៧ ។

[11] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រង់មាត្រា ៣៣៤ (គូសបញ្ជាក់បន្ថែម) ។

[12] សូមមើលឯកសារលេខ E-51/3 "អញ្ញត្រកម្មរួមគ្នា" ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ERN: 00648279-00648310 ។

[13] សារអ៊ីម៉ែលពី Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង ផ្ញើទៅភាគីទាំងអស់, កម្មវត្ថុ៖ ការឆ្លើយតបចំពោះបញ្ហានានាដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ" ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ។

00665551



ឯកសារថ្មីដែលខ្លួនមានបំណងយកទៅសំអាងក្នុងសវនាការនៅពេលវេលាសមស្រប និងឲ្យបានមុនកាលកំណត់នៃការស្នើសុំសម្ភារៈនេះ។ ជំហរនេះនឹងមិនប៉ះពាល់ដល់សិទ្ធិរបស់ នួន ជា ដែលមានចែងនៅក្នុងច្បាប់កម្ពុជា ក្នុងការលើកយកមកសំអាងនូវសម្ភារៈណាមួយដែលគាត់យល់ឃើញថា *មានប្រយោជន៍ដល់ការសំដែងឲ្យឃើញនូវការពិត* ឡើយដរាបណាសម្ភារៈទាំងនេះត្រូវបានដាក់ជូននៅមុនការបិទដំណើការនីតិវិធីពិភាក្សាដេញដោល។ រួមទាំងភស្តុតាងដោះបន្ទុកជាសក្តានុពលដែរ ការដាក់ឯកសារថ្មីនេះ ក៏រួមបញ្ចូលឯកសារទាំងឡាយណាដែលអាចជំទាស់ទៅនឹងភាពអាចជឿជាក់បានរបស់សាក្សីប្រឆាំង។ នៅក្នុងបរិបទនេះ ក្រុមមេធាវីការពារក្តី នួន ជា សូមរក្សាសិទ្ធិទាំងអស់ដែលជនជាប់ចោទមាននៅក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ។

៥. ដូចដែលបានបង្ហាញពីបំណងល្អតាំពីលើកដំបូង ក្រុមមេធាវីការពារក្តី នួន ជា នឹងព្យាយាមដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារទាំងអស់ដែលបានលើកឡើងក្នុងសំណើឲ្យបំពេញកិច្ចស៊ើបសួរផ្សេងៗជាច្រើនកាលពីលើកមុនដែលបានដាក់នៅការិយាល័យសហចៅក្រមស៊ើបអង្កេត[14] ព្រមទាំងសម្ភារៈជាក់លាក់មួយចំនួនទៀតដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមដែលបញ្ជាក់ពីបញ្ហានៃអង្គហេតុនានាដូចដែលបានបង្ហាញនៅក្នុងសេចក្តីសង្ខេបរបស់សាក្សី។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ**

Michel PESTMAN & Victor KOPPE

---

[14] សូមមើលអញ្ញត្រកម្មរួមគ្នា នៅត្រង់កថាខណ្ឌទី ១៨ ។